ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៚ ✵ ៛

ក្រសួងសុខាភិបាល

លេខ. ០៩/០៧/សកប

# ប្រកាស

## ស្តីពី

## ការផ្ទេរប្រតិភូកម្មមុខងារ នៃវិស័យសុខាភិបាល ជូនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការផ្តល់សេវាសាធារណៈរបស់ក្រសួងសុខាភិបាល

---

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស /រកត ០៩១៣ / ៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការ ប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការ បង្កើតក្រសួងសុខាភិបាល

-បានឃើញ ព្រះរាជក្រមលេខ នស /រកម / ១១០០ /១០ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ ២០០០ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ

-បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងសុខាភិបាល

-បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី១០ ខែ ឧសភា ឆ្នាំ ២០១២ ស្តីពីដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-បានឃើញសេចក្តីសម្រេចលេខ ១២ សសរ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបង្កើតការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ស្រុក ខណ្ឌ

-បានឃើញប្រកាសលេខ ០០១៤ អបស / ឱអបស ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ២០០៩ ស្តីពីបែបបទ និងល័ក្ខខ័ណ្ឌ ក្នុងការសុំបើក ឬបិទ ឬសុំប្តូរទីតាំង នៃគ្រឹះស្ថានលក់ឱសថ

-បានឃើញប្រកាសលេខ ០៣៤ អបស /មព ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១១ ស្តីពីការកែសម្រួលបែបបទ និងល័ក្ខខ័ណ្ឌបច្ចេកទេសក្នុងការសុំបើកឬបិទ សុំកែទ្រង់ទ្រាយ ឬប្តូរទីតាំង នៃសេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រឯកជន

-បានឃើញប្រកាសរួមលេខ ១៤៣២ សហវ.ប្រក ចុះថ្ងៃទី២០ ខែ វិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការកែប្រែកម្រងសេវាសាធារណៈ នៃតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ ៩៩៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ

២០១២ ស្តីពីការផ្តល់សេវាសាធារណៈ របស់ក្រសួងសុខាភិបាល

-បានឃើញប្រកាសរួមលេខ ១៤៣៣ សហវ.ប្រក ចុះថ្ងៃទី២០ ខែ វិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការកែប្រែតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ ៩៩៤ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់ រង្វាន់លើកទឹកចិត្តជូនក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញលិខិតលេខ ០០៤ សជណ/គ.ជ.អ.ប ចុះថ្ងៃទី២០ ខែ មករា ឆ្នាំ២០១៤ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

## សម្រេច

**ប្រការ១**.-

ត្រូវបានធ្វើប្រតិភូកម្មមុខងារនៃវិស័យសុខាភិបាល ជូនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ នូវការចេញលិខិតអនុញ្ញាត ក្នុងការផ្តល់សេវាសាធារណៈរបស់ក្រសួងសុខាភិបាល ដោយមានកំណត់ប្រភេទសេវា តម្លៃសេវា រយៈពេលសេវា សុពលភាពសេវា តាមការស្នើបើក ឬបិទ ឬផ្លាស់ប្តូរ ឬបន្តសុពលភាពសេវារដ្ឋបាលសុខាភិបាល ។

ប្រកាសស្តីពីការធ្វើប្រតិភូកម្មនេះ មានវិសាលភាពអនុវត្តទាំងក្រុង ស្រុក ខណ្ឌគោលដៅដែលមានយន្តការផ្តល់សេវារដ្ឋបាលសុខាភិបាល តាមរយៈការិយាល័យច្រកចេញចូលតែមួយ និងរដ្ឋបាល ក្រុង ស្រុក ខណ្ឌដទៃទៀត ដែលមិនទាន់មានយន្តការផ្តល់សេវារដ្ឋបាលសុខាភិបាល តាមរយៈការិយាល័យច្រកចេញចូលតែមួយ។

**ប្រការ២**.-

មុខងារដែលត្រូវបានធ្វើប្រតិភូកម្ម ពីក្រសួងសុខាភិបាល ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ នូវការចេញលិខិតអនុញ្ញាតមាន ៖

-បន្ទប់ពិគ្រោះស្ត្រីមានផ្ទៃពោះមុន និងក្រោយសម្រាល
-បន្ទប់ថែទាំជំងឺ
-បន្ទប់ព្យាបាលដោយចលនា
-ឱសថស្ថានរង ក
-ឱសថស្ថានរង ខ
-បន្ទប់ពិគ្រោះព្យាបាលជំងឺទូទៅ
-បន្ទប់ពិគ្រោះព្យាបាលជំងឺមាត់ធ្មេញ
-ការចេញវិញ្ញាបនបត្របញ្ជាក់សុខភាព ។

**ប្រការ៣**.-

សាលាក្រុង ស្រុក ខណ្ឌ តាមរយៈការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ មានសិទ្ធិព្រមាន ឬផ្អាក ឬ បញ្ឈប់ការបើកសេវារដ្ឋបាលសុខាភិបាល ដែលមានចែងក្នុងប្រការ ២ ក្នុងករណីពិនិត្យឃើញថាៈ

-សាមីជនរៀបចំសេវាមិនសមស្របតាមល័ក្ខខ័ណ្ឌកំណត់របស់ក្រសួងសុខាភិបាល
-សាមីជនមិនគោរពតាមកិច្ចសន្យា និងការណែនាំរបស់ក្រសួងសុខាភិបាល
-សាមីជនមានទោសពីបទល្មើសព្រហ្មទណ្ឌកំរិតមជ្ឈឹម ឬឧក្រិដ្ឋ ។

**ប្រការ៤.-**

តម្លៃសេវា រយៈពេលនៃការផ្តល់សេវា និងសុពលភាពនៃសេវារដ្ឋបាលសុខាភិបាល ត្រូវអនុវត្តតាមប្រកាសរួម របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសុខាភិបាល លេខ ១៤៣២ សហវ.ប្រក ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការកែប្រែកម្រងសេវាសាធារណៈ នៃតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួម លេខ ៩៩៣ សហវ.ប្រក ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១២ ស្តីពី ការផ្តល់សេវាសាធារណៈរបស់ក្រសួងសុខាភិបាល ។

**ប្រការ៥.-**

ប្រធានមន្ទីរសុខាភិបាលរាជធានី ខេត្ត ឬការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ ត្រូវចាត់មន្ត្រីដែលមានសមត្ថភាពសមស្រប ០១ រូប ឲ្យទៅបំពេញការងារជួយដល់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមជំនាញរបស់ខ្លួន ។

**ប្រការ៦.-**

មន្ត្រីទទួលបន្ទុកបច្ចេកទេសសុខាភិបាល ត្រូវរៀបចំគំរូបែបបទផ្សេងៗ រួមទាំងឯកសារពាក់ព័ន្ធសម្រាប់ការចេញលិខិតអនុញ្ញាតទៅតាមប្រភេទសេវារដ្ឋបាលសុខាភិបាល ដែលមានចែងក្នុងប្រការ២ ស្របតាមប្រកាស លេខ ០០១៤ អបស/ឱអបស ចុះថ្ងៃទី១៣ ខែ មករា ឆ្នាំ២០០៩ ស្តីពីបែបបទ និងល័ក្ខខ័ណ្ឌក្នុងការសុំបើក ឬបិទ ឬសុំប្តូរទីតាំង នៃគ្រឹះស្ថានលក់ឱសថ និងប្រកាសលេខ ០៣៤ អបស/មព ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១១ ស្តីពីការកែសម្រួលបែបបទ និងល័ក្ខខ័ណ្ឌបច្ចេកទេស ក្នុងការសុំបើក ឬបិទ សុំកែទ្រង់ទ្រាយ ឬប្តូរទីតាំង នៃសេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រឯកជន ។

**ប្រការ៧.-**

មន្ត្រីទទួលបន្ទុកបច្ចេកទេសសុខាភិបាល ត្រូវធ្វើរបាយការណ៍ទៀងទាត់តាមឋានានុក្រម ប្រចាំខែ ត្រីមាស និងប្រចាំឆ្នាំ ស្តីពីការផ្តល់លិខិតអនុញ្ញាត ដែលមានចែងក្នុងប្រការ២ មកមន្ទីរសុខាភិបាលរាជធានី ខេត្ត ។

**ប្រការ៨.-**

បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៩.-**

អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសសុខាភិបាល អគ្គាធិការក្រសួងសុខាភិបាល និងប្រធានមន្ទីរសុខាភិបាលរាជធានីខេត្ត មានភារៈអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី២០ខែមីនា ឆ្នាំ២០១៥

ម៉ម_ប៊ុនហេង

**កន្លែងទទួល**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យក្រសួងសុខាភិបាល
-គ្រប់សាលារាជធានី-ខេត្ត
-ដូចប្រការ ៩
-ឯកសារ-កាលប្បវត្តិ